**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្ដីក្រើនរំលឹក

## របស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស

ក្រោយពីបានដំណើរការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ (Sinovac) នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩(គ.វ.ក-១៩) បានសង្កេតឃើញថាសកម្មភាពនៃយុទ្ធនាការនេះប្រព្រឹត្តទៅដោយរលូន និងប្រកបដោយការទទួលខុសត្រូវខ្ពស់ពីគ្រប់ក្រុមការងារដែលពាក់ព័ន្ធនៅទូទាំងប្រទេស។ ការខិតខំដោយអស់កម្លាំងកាយចិត្តនេះ នឹងជម្រុញឱ្យការអនុវត្តផែនការនៃការចាក់វ៉ាក់សាំង ជូនប្រជាពលរដ្ឋកម្ពុជាឱ្យកាន់តែមានភាពល្អប្រសើរ និងស្របទៅតាមផែនការមេចាក់វ៉ាក់សាំងកូវីដ-១៩ និងអនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

ដើម្បីឱ្យដំណើរការនៃយុទ្ធនាការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់នៅទូទាំងប្រទេសចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១នេះ កាន់តែមានភាពច្បាស់លាស់ អនុវត្តដោយរលូន និងបានត្រឹមត្រូវថែមទៀតនោះ គ.វ.ក-១៩ សូមធ្វើការក្រើនរំលឹក និងណែនាំបន្ថែមដូចខាងក្រោម៖

**១.ក្រុមអាយុដែលត្រូវចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ (Sinovac) គឺអាយុចាប់ពី១៨ ឆ្នាំ ឡើងទៅ និងត្រូវចាក់ ពីរដូស ដោយគម្លាតពីដូសទីមួយ ទៅដូសទីពីរ មានរយៈពេលពី ១៤ថ្ងៃទៅ ២៨ថ្ងៃ។**

**២.ក្រុមគោលដៅដែលត្រូវចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ក្នុងយុទ្ធនាការនេះមាន៖**

- ក្រុមគ្រូពេទ្យ បុគ្គលិក និងមន្ត្រីសុខាភិបាលជួរមុខ(សេវារដ្ឋ និងសេវាសុខាភិបាលឯកជនស្របច្បាប់ និងដែលមានបញ្ជីឈ្មោះត្រឹមត្រូវបានផ្ញើជូន គ.វ.ក-១៩ ឬទៅមន្ទីរសុខាភិបាលរាជធានី-ខេត្តរួចហើយ) ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលពុំទាន់បានចាក់ពីមុន
- រដ្ឋសភា ព្រឹទ្ធសភា និងក្រុមគ្រួសារដែលមានបញ្ជីឈ្មោះផ្ញើជូន គ.វ.ក-១៩ រួចហើយ
- អ្នកសារព័ត៌មានដែលពុំទាន់បានចាក់ពីមុន( ដែលមានបញ្ជីឈ្មោះត្រឹមត្រូវបានផ្ញើជូន គ.វ.ក-១៩ តាមរយៈក្រសួងព័ត៌មាន ឬទៅមន្ទីរសុខាភិបាលរាជធានី-ខេត្តរួចហើយ )
- កងកម្លាំង និងមន្ត្រីមូលដ្ឋានគ្រប់លំដាប់ថ្នាក់ដែលពុំទាន់បានចាក់ពីមុននៅតាមរាជធានី-ខេត្ត( ចាំបាច់ត្រូវមានបញ្ជីឈ្មោះរៀបចំដោយអាជ្ញាធររាជធានី-ខេត្តពាក់ព័ន្ធ)
- មន្ត្រីរាជការស៊ីវិល រួមទាំងបុគ្គលិកកិច្ចសន្យាទាំងអស់នៅគ្រប់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងសាស្ត្រាចារ្យ គ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលនានាទូទាំងប្រទេស( ដែលបានធ្វើសម្រង់បញ្ជីឈ្មោះដោយក្រសួងអប់រំ យុវជន និងកីឡាដោយបានផ្ញើជូន គ.វ.ក-១៩ រួចហើយ)
- មន្ត្រី-បុគ្គលិកបម្រើការនៃអគ្គិសនីកម្ពុជាទូទាំងប្រទេស និងអាជ្ញាធរជាតិទាំងអស់ គណៈមេធាវី សាលាក្ដីខ្មែរក្រហម លេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុនអាកាសចរនានា ដែលបានផ្ញើឈ្មោះ

ជូន គ.វ.ក-១៩ រួចហើយ

- ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប កាណាឌីយ៉ាគ្រុប ជីបម៉ុងគ្រុប ដែលបានផ្ញើឈ្មោះជូន គ.វ.ក-១៩ រួចហើយ
- កម្មករ-កម្មការិនីនៅតាមរោងចក្រមួយចំនួន(ទៅតាមវេន) ដែលសម្របសម្រួលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានផ្ញើឈ្មោះជូន គ.វ.ក-១៩ រួចហើយ។

**៣.ការរក្សារបៀបរៀបរយ និងរក្សាសុវត្ថិភាពនៅតាមទីតាំងចាក់វ៉ាក់សាំង**

- ត្រូវកំណត់ចំនួនអ្នកត្រូវមកចាក់វ៉ាក់សាំងប្រចាំថ្ងៃនៅតាមទីតាំងចាក់នីមួយៗឱ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមគោលដៅអាទិភាពដែលត្រូវចាក់ដោយកំណត់ចំនួនសមល្មមចៀសវាងមកកកកុញច្រើនដែលជាហេតុបង្កហានិភ័យនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩
- ត្រូវចៀសវាងចាក់វ៉ាក់សាំងខុសក្រុមគោលដៅយុទ្ធនាការលើកនេះដែលបានណែនាំដូចខាងលើ
- ទីកន្លែងចាក់នីមួយៗត្រូវធ្វើរបាយការណ៍ប្រចាំថ្ងៃពីលទ្ធផលការងារនៃការចាក់វ៉ាក់សាំងជូន គ.វ.ក-១៩ ឱ្យបានមុនម៉ោង ១៩:០០នាទី ជារៀងរាល់ថ្ងៃ។

**សម្រាប់វ៉ាក់សាំងកូវីសែល** (Covishield ដែលទទួលបានអាជ្ញាបណ្ណផលិតពីAstraZeneca)

- គ.វ.ក-១៩ សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា តាមការពន្យល់ណែនាំដ៏ទទួច របស់លោកស្រីវេជ្ជបណ្ឌិត លី អាយលែន តំណាងអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា(WHO) បានឱ្យដឹងថា ចន្លោះពេលនៃការចាក់វ៉ាក់សាំងកូវីសែលពីដូសទី១ ទៅដូសទី២ ប្រសិនបើកាន់តែយូរបន្តិច គឺការបង្កើតបាននូវអង់ទីគ័របានកាន់តែល្អ។ ដូច្នេះ WHO ផ្តល់អនុសាសន៍ ឱ្យចាក់លើកទីពីរ នៅក្នុងចន្លោះសប្តាហ៍ទី៨ ទៅទី១២ បន្ទាប់ពីថ្ងៃចាក់លើកទី១ ទើបល្អ។ សូមលោកអ្នកដែលបានចាក់ដូសលើកទី១ រួចហើយនោះ អញ្ជើញមកចាក់ដូសលើកទី២ នៅទីតាំងដែលបុគ្គលបានចាក់លើកទី១ តាមពេលវេលាដែល WHO បានណែនាំនេះ ក៏ប៉ុន្តែសូមមិនអោយលើសពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ ជាកំហិតដោយសារហួសសុពលភាពប្រើប្រាស់របស់វ៉ាក់សាំង។

ថ្ងៃសុក្រ ៥រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២ ខែមេសា ឆ្នាំ២០២១